**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខៈ ០១៧ សសរ គជអប

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងប្រធាន និងអនុប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២ នៃ ផអ៣ របស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងការប្រព្រឹត្តរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
- យោងឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានអនុម័តដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ២០១០

- យោងឯកសារផែនការអនុវត្តរយៈពេល៣ឆ្នាំ២០១១-២០១៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

# សម្រេច

**ប្រការ ១.-**

ត្រូវបានតែងតាំងប្រធាន និងអនុប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២ នៃផែនការអនុវត្តរយៈពេល៣ឆ្នាំ ( ២០១១-២០១៣ ) ដែលទទួលខុសត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **លេខ ទី** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | ប្រធាន |
| ២. | ឯកឧត្តម **អេច ប៊ុនថុល** | អគ្គនាយករង និងជាប្រធាននាយកដ្ឋានបុគ្គលិក និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. | លោក **យិន ម៉ាលីណា** | ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | អនុប្រធាន ។ |

**ប្រការ ២.-**

ប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២ មានភារកិច្ចដឹកនាំក្រុមការងារ ដើម្បីសម្របសម្រួល និងអនុវត្តការងារសំខាន់ៗដូចខាងក្រោម ៖

- រៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អនុកម្មវិធីទី២
- ប្រមូលធាតុចូលនានាដែលជាតម្រូវការរបស់ក្រសួង ស្ថាប័ននានាពាក់ព័ន្ធជាមួយនឹងការអនុវត្តអនុកម្មវិធីទី២
- ដឹកនាំ និងសម្របសម្រួលការអនុវត្ត ផអ៣ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដានការបំពេញការងាររបស់ក្រុមអភិវឌ្ឍន៏សមត្ថភាពថ្នាក់រាជធានី ខេត្ត
- គ្រប់គ្រងកិច្ចសន្យាផ្ដល់ជំនួយបច្ចេកទេស និងកិច្ចសន្យាផ្ដល់សេវាដទៃទៀត ដែលពាក់ព័ន្ធនឹងការអនុវត្តអនុកម្មវិធីទី២
- គ្រប់គ្រងគណនីបំពេញចំណាយរបស់អនុកម្មវិធីទី២
- ធ្វើជាតំណាងក្រសួងមហាផ្ទៃនៅក្នុងកិច្ចប្រជុំ និងសកម្មភាពនានា ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដែលពាក់ព័ន្ធនឹងការអនុវត្ត ផអ៣
- ធ្វើសេចក្ដីរាយការណ៍ជូនលេខាធិការដ្ឋាន គ.ជ.អ.ប និងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ អំពីលទ្ធផលនៃការអនុវត្តអនុកម្មវិធីទី២
- បំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៣.-**

ក្រោមការណែនាំរបស់ប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២ អនុប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីមានភារកិច្ចជួយប្រធានក្រុមការងារ លើកិច្ចការដូចខាងក្រោម ៖

- ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សនៃអនុកម្មវិធីទី២
- ទទួលខុសត្រូវជួយប្រធានក្រុមការងារក្នុងការអនុវត្តភារកិច្ច ដូចបានកំណត់ក្នុងប្រការ ៣ខាងលើ
- ការកសាងផែនការ និងការធ្វើរបាយការណ៍នៃអនុកម្មវិធីទី២
- ការទទួលខុសត្រូវក្នុងការអនុវត្តការងារសំខាន់ៗនៃអនុកម្មវិធីទី២
- បំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២ ។

**ប្រការ ៤.-**

ដើម្បីសម្រេចបាននូវគោលបំណងដែលបានកំណត់នៅក្នុងអនុកម្មវិធីទី២នៃ ផអ៣ ប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីអាចជ្រើសរើស និងសម្រេចតែងតាំងសមាជិកក្រុមការងារតាមការចាំបាច់ ដើម្បីជួយការងាររបស់ខ្លួន។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន គ.ជ.អ.ប អង្គភាពពាក់ព័ន្ធនានាក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

ស ខេង

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- សាលារាជធានីភ្នំពេញ និងគ្រប់សាលាខេត្ត
- ដៃគូអភិវឌ្ឍន៍ផអ៣
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ